# សេចក្តីថ្លែងការណ៍រួម

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧

**នៅក្នុងឱកាសនៃទិវាអន្តរជាតិដើម្បីលើកកម្ពស់សិទ្ធិអ្នកប្លូរភេទ អង្គការសង្គមស៊ីវិល អំពាវឱ្យមានការទទួលយក និងការរួមបញ្ចូលប្រជាពលរដ្ឋខ្មែរដែលជាអ្នកប្លូរភេទ និង ស្នើឱ្យបង្កើតច្បាប់ទទួលស្គាល់និន្នាការភេទ នៅក្នុងឯកសារផ្លូវការនានា**

នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧ នេះ ជាថ្ងៃប្រារព្ធទិវាអន្តរជាតិដើម្បីលើកកម្ពស់សិទ្ធិអ្នកប្លូរភេទលើកទី ៨ ដែលជាការប្រារព្ធប្រចាំឆ្នាំ។ នៅថ្ងៃនេះ យើងខ្ញុំជាអង្គការសង្គមស៊ីវិលដែលមានរាយនាមខាងក្រោម សូមស្នើដល់រាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") ចាត់វិធានការក្នុងការការពារសិទ្ធិរបស់អ្នកប្លូរភេទ រួមទាំងការបង្កើតច្បាប់ដែលមានអានុភាពក្នុងការទទួលស្គាល់សិទ្ធិរបស់អ្នកប្លូរភេទតាមផ្លូវច្បាប់ ដោយយោងទៅតាមការកំណត់យេនឌ័រដោយខ្លួនគេផ្ទាល់។ យើងខ្ញុំក៏សូមអំពាវនាវដល់ប្រជាពលរដ្ឋខ្មែរទាំងអស់មេត្តាទទួលយក ស្រឡាញ់ រាប់អាន និងចូលរួមអបអរដល់ពលរដ្ឋខ្មែរដែលជាអ្នកប្លូរភេទ ក្នុងនាមពួកគាត់ជាអ្នកចូលរួមយ៉ាងពេញលេញក្នុងការអភិវឌ្ឍ និងសង្គមកម្ពុជា។

ទិវាអន្តរជាតិដើម្បីលើកកម្ពស់សិទ្ធិអ្នកប្លូរភេទ គឺជាទិវានៃការផ្តល់អំណាច និងការអបអរចំពោះសហគមន៍អ្នកប្លូរភេទ។ ប្រធានបទសម្រាប់ទិវាឆ្នាំនេះ គឺការតស៊ូរបស់អ្នកប្លូរភេទ (#ការតស៊ូរបស់អ្នកប្លូរភេទ) ហើយទិវានេះជាការលើកទឹកចិត្តឱ្យមានការបង្ហាញជាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងអារម្មណ៍រើសអើងលើអ្នកប្លូរភេទ ជំរុញឱ្យអ្នកប្លូរភេទចេះតស៊ូប្រឆាំងនឹងការធ្វើទុក្ខបុកម្នេញលើខ្លួន និងលើកស្ទួយយុត្តិធម៌សម្រាប់អ្នកប្លូរភេទ។ ថ្ងៃនេះគឺជាឱកាសសម្រាប់ការពិភាក្សា ការអប់រំ និងការធ្វើសកម្មភាពទាក់ទងនឹងសិទ្ធិ និងបញ្ហានានារបស់សហគមន៍អ្នកប្លូរភេទ។

នៅខែកញ្ញា ឆ្នាំ២០១៦ ម.ស.ម.ក បានចេញផ្សាយរបាយការណ៍មួយមានចំណងជើងថា៖ "*ការរើសអើងលើអ្នកប្លូរភេទជាស្ត្រីនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា*" ដែលបានបង្ហាញពីការយាយី និងការរើសអើងផ្សេងៗដែលកើតមានជារៀងរាល់ថ្ងៃដ៏គួរឱ្យព្រួយបារម្ភ ដែលអ្នកប្លូរភេទជាស្ត្រីជួបប្រទះនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍នេះបានលើកឡើងថា អ្នកឆ្លើយតបស្ទើរតែទាំងអស់ (ចំនួន៩២%) បាននិយាយថាពួកគាត់ធ្លាប់រងការយាយីតាមរយៈពាក្យសំដី ចំនួន ៤៣% បានរាយការណ៍ថាធ្លាប់រងការបំពានលើរាងកាយ និងចំនួន ៣១% ធ្លាប់រងការបំពានផ្លូវភេទនៅពេលកំពុងធ្វើដំណើរនៅលើដងផ្លូវ។ ការស្រាវជ្រាវនេះក៏បានរកឃើញផងដែរថា តម្លៃគ្រួសារតាមបែបប្រពៃណីប៉ះពាល់យ៉ាងខ្លាំងដល់ជីវិតរបស់អ្នកប្លូរភេទនៅក្នុងប្រទេសកម្ពុជា។ ជារឿយៗ ក្រុមគ្រួសាររបស់អ្នកប្លូរភេទមួយចំនួនពុំបានយល់ដឹង និងទទួលយកអ្នកប្លូរភេទឡើយ ដោយចំនួន ៤៩% នៃអ្នកឆ្លើយតបបានរាយការណ៍ថា ពួកគាត់មានអារម្មណ៍ថាខ្លួនត្រូវតែចាកចេញពីផ្ទះដោយសារតែអត្តសញ្ញាណប្លូរភេទរបស់ខ្លួន។ ជាងពាក់កណ្តាលនៃអ្នកឆ្លើយតបប្រាប់ថា សមាជិកគ្រួសារគាត់បានព្យាយាមបង្ខិតបង្ខំខ្លួនឱ្យរៀបអាពាហ៍ពិពាហ៍ជាមួយមនុស្សដែលមានភេទខុសគ្នា។ រយៈពេលជិត ៦ ខែ

ចាប់តាំងពីមានការចេញផ្សាយរបាយការណ៍នេះ យើងឃើញមានការវិវឌ្ឍតិចតួចក្នុងការលើកកម្ពស់សិទ្ធិរបស់អ្នកប្តូរភេទ។ នៅពេលចេញផ្សាយរបាយការណ៍ តំណាងរដ្ឋាភិបាលមួយចំនួនបានច្រានចោលអនុសាសន៍ក្នុងរបាយការណ៍ ដែលស្នើឱ្យមានការបង្កើតច្បាប់ជាក់លាក់មួយដើម្បីហាមឃាត់ការរើសអើង ដោយបានអះអាងថាក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ គឺគ្រប់គ្រាន់ហើយក្នុងការការពារពលរដ្ឋខ្មែរដែលជាអ្នកប្តូរភេទ។ របាយការណ៍ និងការឆ្លើយតបបែបនេះរដ្ឋាភិបាលបង្ហាញថា មានការងារសំខាន់ៗជាច្រើនដែលត្រូវធ្វើដើម្បីការពារ និងលើកកម្ពស់សិទ្ធិរបស់ពលរដ្ឋខ្មែរដែលជាអ្នកប្តូរភេទ។

ការបង្កើតច្បាប់ដែលសម្រួលដល់សិទ្ធិក្នុងការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ គឺជាការងារដ៏ចាំបាច់មួយនៅកម្ពុជា។ ដូចមានចែងក្នុងគោលការណ៍ទី៣ នៃ គោលការណ៍យ៉ូក៏យ៉ាកាតា ឆ្នាំ២០០៦ ស្តីពីគោលការណ៍នៃការអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិស្តីពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ("គោលការណ៍យ៉ូក៏យ៉ាកាតា") *«និន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់បុគ្គលម្នាក់ៗមានសារៈសំខាន់សម្រាប់បុគ្គលិកលក្ខណៈរបស់បុគ្គលនីមួយៗ ហើយក៏ជាទិដ្ឋភាពមូលដ្ឋាននៃការតាំងចិត្តផ្ទាល់ខ្លួន សេចក្តីថ្លៃថ្នូរ និងសេរីភាព»*។ "គោលការណ៍ទី ៣" បង្គាប់ឱ្យរដ្ឋជានាឱ្យមានវិធានការផ្នែកច្បាប់ និងរដ្ឋបាល ដើម្បីអាចឱ្យមានការបញ្ជាក់ពីយេនឌ័ររបស់បុគ្គលម្នាក់ៗដែលកំណត់ដោយអ្នកប្តូរភេទខ្លួនឯងផ្ទាល់នៅលើឯកសារផ្លូវការរបស់ពួកគាត់ ដូចជាសំបុត្រកំណើត លិខិតឆ្លងដែន និងប័ណ្ណបើកបរជាដើម។ លិខិតគតិយុត្តដែលធានាដល់សិទ្ធិរបស់ប្តូរភេទក្នុងការប្តូរយេនឌ័ររបស់ខ្លួននៅលើឯកសារផ្លូវការ ក៏នឹងអាចឱ្យដៃគូស្នេហា ដែលក្នុងនោះមានដៃគូម្នាក់តាំងខ្លួនជាអ្នកប្តូរភេទរៀបការស្របតាមលក្ខខណ្ឌច្បាប់តម្រូវក្នុងនាមជា "*ប្តី*" និង "*ប្រពន្ធ*"។ យើងខ្ញុំសូមស្នើថាលិខិតគតិយុត្តនេះគួរតែបង្កើតឡើងក្នុងទម្រង់មួយដែលសាមញ្ញ មិនមានការប្រឈម និងតាមបែបបទរដ្ឋបាល ជាជាងតាមនីតិវិធីតុលាការ ក្នុងការកែប្រែលើឯកសារផ្លូវការស្របទៅតាមនិន្នការ និងអត្តសញ្ញាណយេនឌ័រ។

យើងខ្ញុំក៏សូមអំពាវនាវផងដែរដល់សាធារណជនខ្មែរ និងជាពិសេស ឪពុកម្តាយដែលមានកូនជាស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរភេទ និងអ្នកមាននិន្នាការភេទមិនប្រាកដ "អ្នកស្រឡាញ់ភេទដូចគ្នា" មេត្តាទទួលយក និងផ្តល់តម្លៃដល់អ្នកប្តូរឱ្យស្មើភាពគ្នា ព្រមទាំងទទួលយកវប្បធម៌នៃការអត់ឱន ការរួមបញ្ចូល និងការមិនរើសអើង។ សិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នា គឺជាសិទ្ធិមនុស្ស ហើយបុគ្គលគ្រប់រូបត្រូវតែទទួលបានការការពារពីការប្រព្រឹត្តមិនត្រឹមត្រូវ ការយាយី និងការរើសអើងដោយផ្អែកលើនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេ។

**ណុយ ស៊ីថា សកម្មជនអ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរភេទជាបុរសមានប្រសាសន៍ថា ៖**

*«ការទទួលស្គាល់តាមផ្លូវច្បាប់ចំពោះយេនឌ័រដែលកំណត់ដោយបុគ្គលម្នាក់ៗ គឺមានសារៈសំខាន់ចំពោះសេចក្តីថ្លៃថ្នូរ និងសិទ្ធិរបស់អ្នកប្តូរភេទ។ នៅរាល់ពេលដែលខ្ញុំមើលប័ណ្ណបើកបរ ឬអត្តសញ្ញាណប័ណ្ណរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាប្រទេសរបស់ខ្ញុំកំពុងបដិសេធអត្តសញ្ញាណពិតរបស់ខ្ញុំ។ គ្រប់ពេលធ្វើឱ្យខ្ញុំមានអារម្មណ៍ឈឺចាប់។ ការផ្លាស់ប្តូរឯកសារទាំងនេះដើម្បីឆ្លុះបញ្ចាំងពីអត្តសញ្ញាណយេនឌ័រជាបុរសរបស់ខ្ញុំអាចនឹងផ្លាស់ប្តូរអារម្មណ៍បែបនេះរបស់ខ្ញុំបាន។ ការធ្វើបែបនេះក៏អាចឱ្យខ្ញុំរៀបការជាមួយដៃគូរបស់ខ្ញុំបានទៀតផង។ ខ្ញុំ*

*សូមសំណូមពរដល់រដ្ឋាភិបាលកម្ពុជាមេត្តាផ្តល់យុត្តិធម៌ឱ្យខ្ញុំ និងអ្នកប្តូរភេទផ្សេងទៀត តាមរយៈការផ្លាស់ប្តូរលិខិតគតិយុត្តយ៉ាងសាមញ្ញមួយនេះ។»*

**លោក នួន ស៊ីដារ៉ា អ្នកសម្របសម្រួលគម្រោងសូជី ម.ស.ម.ក មានប្រសាសន៍ថា៖**

*«មានតម្រូវការចាំបាច់ក្នុងការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់នៅក្នុងប្រទេសកម្ពុជា។ ការបង្កើតច្បាប់មួយដែលលទទួលស្គាល់អត្តសញ្ញាណយេនឌ័រនៅក្នុងឯកសារផ្លូវការនានា ស្របតាមនិន្នាការអន្តរជាតិនឹងជាការវិវត្តវិជ្ជមានមួយឆ្ពោះទៅដល់ការផ្តល់សិទ្ធិស្មើគ្នាសម្រាប់សហគមន៍អ្នកប្តូរភេទ។ ករណីនេះគួរតែជាបញ្ហាអាទិភាពមួយរបស់រដ្ឋាភិបាលក្នុងការគោរពអត្តសញ្ញាណយេនឌ័រដែលកំណត់ដោយបុគ្គលម្នាក់ៗនៅកម្ពុជា ទាំងផ្លូវច្បាប់ និងទិដ្ឋភាពសង្គម។»*

**អង្គការសង្គមស៊ីវិលដែលគាំទ្រសេចក្តីថ្លែងការណ៍នេះ រួមមាន ៖**

1. អង្គការអនាគតយុវជនកម្ពុជាអាស៊ាន សូមទាក់ទង លោក ស្រ៊ុន ស្រ៊ន ស្ថាបនិក តាមរយៈអ៊ីម៉ែល៖ ssrorn09@gmail.com ឬ ទូរសព្ទ៖ 093 600 234
2. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សូមទាក់ទង លោក នួន ស៊ីដារ៉ា អ្នកសម្របសម្រួលគម្រោងសូជី តាមរយៈអ៊ីម៉ែល៖ sidara.nuon@cchrcambodia.org ឬ ទូរសព្ទ៖ 097 9666 566
3. អង្គការខាណា សូមទាក់ទង លោក ជួប សុខចំរើន នាយកប្រតិបត្ត តាមរយៈអ៊ីម៉ែល៖ csokchamreun@khana.org.kh
4. អង្គការខេមរា សូមទាក់ទង លោកស្រី កុយ ផល្លានី នាយិកាប្រតិបត្តិ តាមរយៈអ៊ីម៉ែល៖ khemara.ed@khemaracambodia.org
5. សមាគមយុវជនខ្មែរ សូមទាក់ទង កញ្ញា តាន់ គីម ហេង ប្រធាន តាមរយៈអ៊ីម៉ែល៖ president@kya-cambodia.org
6. អង្គការសកម្មភាពផ្សព្វផ្សាយដើម្បីអប់រំ និងអភិវឌ្ឍន៍ សូមទាក់ទង លោក កយ បូរី នាយកប្រតិបត្តិ តាមរយៈអ៊ីម៉ែល៖ kborey@mediaone.org.kh
7. អង្គការសេវាសង្គមសុខភាពបុរស សូមទាក់ទង លោក ដោក បញ្ញា នាយកប្រតិតបត្តិ តាម រយៈអ៊ីមែល៖ pagnamhss@yahoo.com
8. អង្គការសុខភាពបុរសកម្ពុជា សូមទាក់ទង លោក ម៉ៅ គីមរុន នាយកប្រតិបត្តិ តាមរយៈអ៊ីម៉ែល៖ kimrunmao@gmail.com
9. សហគមន៍ឥន្ទធនូកម្ពុជា សូមទាក់ទង កញ្ញា ហេង ជ័យលាភី តាមរយៈអ៊ីម៉ែល៖ leaphy@rockcambodia.org
10. បណ្តាញយុវជនងាយរងគ្រោះកម្ពុជា សូមទាក់ទង លោក ផង់ ចន្ថន អ្នកសម្របសម្រួល តាមរយៈអ៊ីម៉ែល៖ pchanthorn@khana.org.kh